ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អ អ ក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ២៧៤ សាគ.១៧ អអក

ភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណលើកទី១
# របស់ក្រុមហ៊ុន អាយអ៊ីឌី-អ៊ិនវេស(ខេមបូឌា)

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលឯកសារអាជ្ញាបណ្ណ ក្រុមហ៊ុន អាយអ៊ីឌី-អ៊ិនវេស(ខេមបូឌា) ដោយអនុញ្ញាតឲ្យក្រុមហ៊ុនបន្ថែមសេវាកម្មផលិតអគ្គិសនីអានុភាព ២ម៉េហ្គាវ៉ាត់ នៅភូមិស្រអែម ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ លើសេវាកម្មផលិតអគ្គិសនីដែលមានស្រាប់នៅភូមិដូនស្វា ឃុំចារឈូក ស្រុកអង្គរជុំ ខេត្តសៀមរាប តាមខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដូចមានភ្ជាប់មកជាមួយ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជា អាជ្ញាធរមូលដ្ឋាន ស្ថាប័នរដ្ឋនានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យ ផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា លើសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដែលគ្រោងនឹងផ្តល់ជូននេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជា នឹងតម្កល់ទុកសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន អាយអ៊ីឌី-អ៊ិនវេស(ខេមបូឌា) នៅ……………………………………………………………………………

……………………………………………សម្រាប់សាធារណជនពិនិត្យ។

អាស្រ័យហេតុនេះ សូមសាធារណជនរស់នៅឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់ លើសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យក្រុមហ៊ុន អាយអ៊ីឌី-អ៊ិនវេស(ខេមបូឌា) អាចអញ្ជើញមកទីកន្លែងខាងលើ ដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា ចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៧ ។

អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា " **អាជ្ញាធរអគ្គិសនីកម្ពុជានឹងពិចារណាតែចំពោះមតិយោបល់ណាដែលបានបង្ហាញនូវហេតុផលយោងច្បាស់លាស់ប៉ុណ្ណោះ** " ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវកាត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
**ទូរស័ព្ទ** : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ **ទូរសារ** : ០២៣ ២១៤ ១៤៤, **អ៊ីម៉ែល** : admin@eac.gov.kh ; Website : www.eac.gov.kh

**សេចក្តីព្រាង**
សម្រាប់ពិគ្រោះយោបល់ពីថ្ងៃជូនដំណឹង
រហូតដល់ថ្ងៃទី៣០..ខែកក្កដា..ឆ្នាំ២០១៧

# អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# សេចក្តីកែសម្រួលលើកទី១

## លើឯកសារអាជ្ញាបណ្ណផលិតកម្មលេខ ៣៦៦ ឯអ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ សម្រាប់ក្រុមហ៊ុន អាយអ៊ីឌី-អ៊ិនវេស(ខេមបូឌា) សម្រាប់ការធ្វើសេវាកម្មផលិតអគ្គិសនីនៅភូមិដូនស្វា ឃុំចារឈូក ស្រុកអង្គរជុំ ខេត្តសៀមរាប និងបន្ថែមកម្លាំងផលិតអគ្គិសនីនៅភូមិស្រះអែម ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

# DECISION ON FIRST REVISION

## OF THE GENERATION LICENSE DOCUMENT N° 366 LD DATED SETEMBER 25, 2013 FOR IED-INVEST (CAMBODIA) CO., LTD FOR PROVIDING ELECTRIC POWR GENERATION SERVICE AT PHUM DAUNSVA, KHUM CHAR CHHOUK, ANGKOR CHUM DISTRICT, SIEM REAP PROVINCE AND ADDITION OF ELECTRIC POWER GENERATION SERVICE AT SRA'AEM VILLAGE, KANTOUT COMMUNE, CHOAM KSANT DISTRICT, PREAH VIHEAR PROVINCE.

ថ្ងៃទី ខែ ឆ្នាំ២០១៧

... / ....